**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**ស្តីពី**

**ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត**

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០

**រវាង**

ក្រុមហ៊ុន **ខ្វាន់ខុម អឺកែរីល (ខេមបូឌា) លីមីធីត** មានទីតាំងស្ថិតនៅអគារលេខ ១១ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅ ហៅថា ភាគី "ក"។

**ជាមួយនឹង**

កម្មករនិយោជិតនៃក្រុមហ៊ុន **ខ្វាន់ខុម អឺកែរីល (ខេមបូឌា) លីមីធីត** មានទីតាំងស្ថិតនៅអគារលេខ ១១ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលតំណាងដោយប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ចាប់ពីពេលនេះតទៅហៅថា ភាគី "ខ"។

**ដោយហេតុថា**

១- **ដោយហេតុថា៖** ភាគី "ក" ជួបការលំបាកផ្នែកសេដ្ឋកិច្ចដោយមូលហេតុចំនួន ០២ គឺការឆ្លងរាលដាលជាសកលនៃមេរោគកូវីដ-១៩ និងការផ្តាច់ប្រព័ន្ធអនុគ្រោះពន្ធ (EBA) របស់សហគមអឺរ៉ុប ដែលនាំឲ្យមានការកាត់បន្ថយការបញ្ជាទិញចំនួន ៣០% (សាមសិប) ភាគរយ។

២- **ដោយហេតុថា៖** ភាគី "ក" មានបំណងចង់ព្យួរកិច្ចសន្យាការងារ មានថិរវេលា ២ (ពីរ) ខែ។

៣- **ដោយហេតុថា៖** ភាគី "ក" និងភាគី "ខ" បានពិភាក្សាគ្នា និងបានព្រមព្រៀងគ្នារួចហើយ។

**ក្រោយពីបានពិភាក្សាគ្នាមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖**

**ប្រការ១៖ ការព្រមព្រៀង**

១.១- ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងព្យួរកិច្ចសន្យាការងារ មានថិរវេលាចំនួន ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី០៩ ខែកញ្ញា ដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ២០២០។

១.២-កម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារ មានចំនួន ១៩០ (ពីររយសែសិបមួយ) នាក់ ដែលធ្វើការនៅក្នុងផ្នែកជាច្រើន ដែលគ្មានការងារធ្វើ។

១.៣-ចំពោះកម្មករនិយោជិតដែលមានផ្ទៃពោះ ក្រុមហ៊ុននឹងមិនព្យួរកិច្ចសន្យាការងារទេ។

**ប្រការ២- ការផ្តល់ប្រាក់ឧបត្ថម្ភ**

២.១- ភាគី "ក" យល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភដល់ភាគី "ខ" ក្នុង១ខែចំនួន ៣០ (សាមសិប) ដុល្លារអាមេរិក និងរាជរដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភក្នុង១ខែចំនួន៤០ (សែសិប) ដុល្លារអាមេរិក។

២.២- ភាគី "ក" យល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភដល់ភាគី "ខ" បន្ថែមចំនួន ៣ (បី) ថ្ងៃ។

២.៣- ប្រាក់ឧបត្ថម្ភនៃការព្យួរការងារនេះ ក្រុមហ៊ុននឹងបើកជូនសរុបចំនួន ២ (ពីរ) ខែ តែម្តង។

២.៤- ក្រុមហ៊ុននឹងផ្តល់ជូនប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ៥ (ប្រាំ) ដុល្លារអាមេរិក និងប្រាក់ថ្លៃធ្វើដំណើរចំនួន ១២ (ដប់ពីរ) ដុល្លារអាមេរិក សម្រាប់ខែកញ្ញា ឆ្នាំ២០២០។

**ប្រការ៣- របៀបបើកប្រាក់ឧបត្ថម្ភ**

ភាគី "ក" នឹងបើកប្រាក់ឈ្នួលសម្រាប់ខែកញ្ញា ប្រាក់ឧបត្ថម្ភនៃការព្យួរការងារ ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៣ (បី) ថ្ងៃ ប្រាក់រង្វាន់ការងារទៀងទាត់ និងប្រាក់ថ្លៃធ្វើដំណើរជូនភាគី "ខ" នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។

**ប្រការ៤- អវសានប្បញ្ញត្តិ**

៤.១- ភាគីទាំងពីរបានអាន និងយល់ច្បាស់គ្រប់ប្រការដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះហើយភាគីទាំងពីរបានឯកភាពគ្នាចុះហត្ថលេខាដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

៤.២- កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរ ចំនួន០៣ច្បាប់ ដោយរក្សាទុកនៅ៖

-ភាគី "ក" ចំនួន ០១ (មួយ) ច្បាប់។

-ភាគី "ខ" ចំនួន ០១ (មួយ) ច្បាប់។

-ការិយាល័យមេធាវី ចំនួន ០១ (មួយ) ច្បាប់។

៤.៣-កិច្ចព្រមព្រៀងនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខារបស់ភាគីទាំងពីរតទៅ។

**តំណាងភាគី "ក"**

QUANTUM APPAREL (CAMBODIA) LIMITED

Sajith Abey...

**តំណាងភាគី "ខ"**

CHAYNA

yom pheakin

Vanlida loek.

**បានឃើញ និងបញ្ជាក់ថា**

ភាគីទាំងពីរពិតជាបានចុះហត្ថលេខា

និងផ្តិតស្នាមមេដៃស្តាំនៅចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី ហ៊ំ_តារា